ឃ្លាំមើលសភា តំណាងរាស្ត្រ

របាយការណ៍ឆ្នាំទី១ លេខ៣ នីតិកាលទី ៤ ប្រចាំខែ ធ្នូ ២០០៨-មករា ២០០៩

# បទបញ្ជាផ្ទៃក្នុងរដ្ឋសភាធ្វើឱ្យតំណាងរាស្ត្រគណបក្សមានអាសនៈតិចបាត់បង់សិទ្ធិបញ្ចេញមតិ

តំណាងរាស្ត្រគណបក្ស សិទ្ធិមនុស្ស ទាំង៣ រូប បានបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការបញ្ចេញមតិនៅក្នុងសម័យប្រជុំសភាពេញអង្គ ដោយសារតែការធ្វើពហិការមិនចូលរួមជាមួយក្រុមមបញ្ចេញមតិមកពីគណបក្សដ៏ទៃទៀត។ ប្រធានគណបក្សសិទ្ធិមនុស្ស អ្នកតំណាងរាស្ត្រ **កឹម សុខា** បានមានប្រសាសន៍ថា *"នឹងមិនចូលជាមួយក្រុមបញ្ចេញមតិផ្សេងទេ ដោយសារយើងជាគណបក្សនយោបាយមួយ ឱ្យយើងទៅក្រោមគណបក្សដទៃ វាមិនសមរម្យតាមគោលការណ៍ប្រជាធិបតេយ្យ។"*

អ្នកតំណារាស្ត្ររូបនេះបានឱ្យដឹងថា ក្រុមតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ដែលមានចំនួន ៣រូប ស្នើសុំវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរដ្ឋសភាដើម្បីឱ្យគណបក្សមានអាសនៈតិចជាង ១០ អាចបង្កើតក្រុមបញ្ចេញមតិបាន *"យើងបានស្នើឱ្យកែប្រែបទបញ្ជាផ្ទៃក្នុងយូរហើយ តែនៅមិនទាន់មានការឆ្លើយតបពីប្រធានរដ្ឋសភា... បើមិនមានការឆ្លើយតបទេ យើងនឹងធ្វើពហិការពេញមួយអណត្តិតែម្តង ដើម្បីឱ្យមតិជាតិ និងអន្តរជាតិដឹងថាសភានេះមិនមានលក្ខណៈសេរី និងត្រឹមត្រូវទេ។"* អ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** មកពីគណបក្សសិទ្ធិមនុស្ស បន្ថែមថា ការមិនអនុញ្ញាតឱ្យគណបក្ស សិទ្ធិមនុស្ស បញ្ចេញមតិគឺដូចជាបំបិទមាត់របស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។

សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាតំណាងរាស្ត្រមណ្ឌលកំពង់ចាមមកពី គណបក្សប្រជាជនកម្ពុជា ធ្លាប់បានមានប្រសាសន៍ក្នុងសម័យប្រជុំពេញអង្គសភាថា អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សនឹងមិនមានសិទ្ធិបញ្ចេញមតិរហូត បើអ្នកតំណាងរាស្ត្រទាំងនេះមិនចូលរួមជាមួយក្រុមដទៃទេនោះ។

តំណាងរាស្ត្រមណ្ឌលភ្នំពេញ **សុន ឆ័យ** ក៏បានគាំទ្រឱ្យមានការធ្វើវិសោធនកម្មដើម្បីឱ្យគណបក្សដែលមានអាសនៈតិចជាង១០ អាចបង្កើតក្រុមបញ្ចេញមតិបានមួយក្រុម *"... គណបក្សមួយដែលមាន៣នាក់ គួរតែយើងពិនិត្យកែសម្រួលយ៉ាងម៉េច ឱ្យគណបក្សទាំងឡាយដែលប្រជារាស្ត្រជ្រើសតាំងមកនេះឱ្យបាននិយាយក្នុងនាមប្រជារាស្ត្រដែលគាំទ្រគាត់ផង ឱ្យមានសម្លេងផង នេះសូមការពិនិត្យពីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាអាចពិនិត្យលើករណីនេះ។"*

ក្នុងនីតិកាលទី៤នេះ រដ្ឋសភាមានក្រុមបញ្ចេញមតិពិភាក្សាចំនួន១១ ដែលក្នុងនោះគណបក្សប្រជាជនកម្ពុជាមាន ៩ក្រុម ក្នុងនោះមានសមាជិករដ្ឋសភាមកពីគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិផងដែរ។ ចំណែកគណបក្ស សមរង្ស៊ី មាន ២ក្រុម។ នៅតែគណបក្សសិទ្ធិមនុស្សមិនទាន់មានក្រុមបញ្ចេញមតិ។ សូមរំលឹកដែរថា រដ្ឋសភា ក្រោមហេតុផលដើម្បីឱ្យមានសណ្តាប់ធ្នាប់ក្នុងសម័យប្រជុំរដ្ឋសភាបានធ្វើវិសោធនកម្ម បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្នុងឆ្នាំ ២០០៥ ដែលតម្រូវឱ្យសមាជិករដ្ឋសភាអាចឡើងបញ្ចេញមតិបានលុះត្រាតែខ្លួនជា សមាជិកក្រុមឡើងបញ្ចេញមតិក្នុងរដ្ឋសភា ដែលតម្រូវមួយក្រុមមានសមាជិកយ៉ាងតិច ១៣ រូប។ ទោះបីយ៉ាងណា ក្រោយពីការត្រូវរ៉ូវគ្នាផ្នែកនយោបាយរវាងគណបក្សសមរង្ស៊ី និងគណបក្សកាន់អំណាចប្រជាជនកម្ពុជាក្នុងឆ្នាំ ២០០៦ ខុមប្រែ្វលសង្កេតឃើញថាមានការកែលំអដ៏ប្រសើរមួយជំហានទៀត ដោយរដ្ឋសភាបានធ្វើវិសោធនកម្ម

មាតិកា:

- អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងនៅតែជួបឧបសគ្គក្នុងការបំពេញតួនាទីរបស់ខ្លួន............................................ ២
- តំណាងរាស្ត្រឱ្យរដ្ឋាភិបាលបំភ្លឺរឿងវិបត្តិសេដ្ឋកិច្ច និងដីធ្លី..... ៣
- ដំណើរការសម័យប្រជុំសភាពេញអង្គ..............................៤

ប្រការ ៤៨ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាក្នុងខែមេសា ឆ្នាំ២០០៦ ដោយបន្ថយចំនួនសមាជិកក្រុមឡើងបញ្ចេញមតិពី ១៣ រូប ក្នុងមួយក្រុម មកត្រឹមតែ១០ រូប វិញក្នុងមួយក្រុម ។

អ្នកឯកទេសច្បាប់បានលើកឡើង ថា " *រដ្ឋសភាកម្ពុជា បានលើកហេតុផលថា ការបង្កើតក្រុមនេះគឺយកគំរូតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសអាឡឺម៉ង់ តែជាក់ស្តែង ការបង្កើតក្រុមអ្នកតំណាងរាស្ត្រក្នុងរដ្ឋសភាប្រទេសនេះ គឺដើម្បីតំណាងឱ្យគណបក្សនយោបាយនីមួយៗដែលមានអាសនៈក្នុងរដ្ឋសភាតែប៉ុណ្ណោះ មិនមែនសំរាប់ចែកជាចំនួនក្រុមឡើងបញ្ចេញមតិទេ ពោលគឺបើក្នុងរដ្ឋសភារបស់ប្រទេសអាឡឺម៉ង់ គណបក្សនយោបាយជាប់ឆ្នោតចំនួន ៣ ដូចនេះរដ្ឋសភានឹងមានតែ ៣ ក្រុមអ្នកតំណាងរាស្ត្រប៉ុណ្ណោះសំរាប់តំណាងឱ្យគណបក្សនីមួយៗ ។*"

## អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងនៅតែជួបឧបសគ្គក្នុងការបំពេញតួនាទីរបស់ខ្លួន

ក្នុងរយះពេល៤ខែ បន្ទាប់ពីរដ្ឋសភានីតិកាលទី៤ បានបង្កើត អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងនៅតែជួបឧបសគ្គក្នុងការទទួលបានពត៌មានទាក់ទងនឹងសេចក្តីព្រាងច្បាប់ ដែលចូលដល់គណៈកម្មការជំនាញរដ្ឋសភា ដោយសារតែគ្មានអ្នកតំណាងរាស្ត្រណាម្នាក់ក្នុងគណបក្សនេះមានតួនាទីក្នុងគណៈកម្មការជំនាញរដ្ឋសភា ។

អ្នកតំណាងរាស្ត្រ **គីម សួរភិរិទ្ធ** មកពីគណបក្សសមរង្ស៊ី លើកឡើងពីផលលំបាកខ្លួនថា "*យើងមិនដឹងថា ច្បាប់ណាគេសុំកែយ៉ាងម៉េច ហើយរាល់សេចក្តីព្រាងច្បាប់ទាល់តែឆ្លងគណៈកម្មការជំនាញ និងរបៀបវារៈទើបខ្ញុំបានទទួល ។*"

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** មណ្ឌលភ្នំពេញមកពីគណបក្ស សមរង្ស៊ី និងធ្លាប់ជាប្រធានគណៈកម្មការជំនាញទី ៤ នៃរដ្ឋសភានីតិកាលទី ៣ ទទួលបន្ទុកមហាផ្ទៃ អង្កេត បោសសំអាត និងមុខងារសាធារណៈ បាននិយាយថា ការគ្មានវត្តមាននៅក្នុងគណៈកម្មការជំនាញ ឬអចិន្ត្រៃយ៍ គឺមានន័យថា តំណាងរាស្ត្រគឺចាំតែចូលប្រជុំពេញអង្គតែប៉ុណ្ណោះ ។ អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** បានបន្តទៀតថា "*កាលយើងនៅក្នុងគណៈកម្មការ គឺយើងទទួលបានពត៌មានច្រើនទាក់ទងនឹងសេចក្តីព្រាងច្បាប់ ឬសម័យប្រជុំនានា ហើយយើងអាចមានពេលច្រើនដើម្បីសិក្សា និងកែប្រែសេចក្តីព្រាងច្បាប់ និងរបៀបវារៈនានាដើម្បីផ្តល់អនុសាសន៍ និងពន្លឿនដល់កិច្ចប្រជុំសភាពេញអង្គ...តែឥឡូវគឺ ពត៌មានអត់មានទេ ។*"

អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស **យ៉ែម បុញ្ញប្ញទ្ធិ** បានបង្ហាញផលលំបាកដូចគ្នានេះដែរ ក៏ប៉ុន្តែអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី និងសិទ្ធិមនុស្ស ក៏បានលើកឡើងផងដែរថា បើទោះបីជាចូលគណៈកម្មការជំនាញរដ្ឋសភាក៏ខ្លួនគ្មានឥទ្ធិពលអ្វីឡើយ ប្រសិនបើបទបញ្ជាផ្ទៃក្នុងរដ្ឋសភាមិនត្រូវបានធ្វើវិសោធនកម្មដើម្បីធានាដល់តួនាទីរបស់គណបក្សប្រឆាំង ។

តំណាងរាស្ត្រគណបក្ស សមរង្ស៊ី កាលពីខែ តុលា ឆ្នាំ ២០០៨ ធ្លាប់បានស្នើធ្វើវិសោធនកម្មនេះម្តងហើយ តែត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបដិសេធចោលដោយចំនួនតំណាងរាស្ត្រស្នើសុំមិនគ្រប់ចំនួន ៣១ រូប តាមនីតិវិធី ហើយអនុប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានប្រកាសជាសាធារណៈថា នឹងគ្មានការកែប្រែបទបញ្ជាផ្ទៃក្នុងនោះទេ។ សម្តេចបានលើកឡើងថា "*ការស្នើសុំកែប្រែហ្នឹង ហួសហេតុ មិនអាចទទួលយកបានដោយកែដល់ទៅ ២៦ លើ ៨២ ចំនុច ហើយសុទ្ធតែកន្លែងខ្លាញ់ មិនអាចឱ្យបានទេ ។*"

ខ្លឹមសារសំខាន់ៗនៃវិសោធនកម្មលើបទបញ្ជាផ្ទៃក្នុងនេះរួមមាន ការបែងចែកអំណាចប្រធានរដ្ឋសភាទៅតាមការស្នើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេក្នុងរដ្ឋសភា អនុប្រធានទីមួយតាមការស្នើរបស់គណបក្សមានអាសនៈច្រើនលំដាប់ទី ២ និងអនុប្រធានទី២ តាមការស្នើរបស់គណបក្សច្រើនលំដាប់ទី៣ ហើយក៏មានការបែងចែកអំណាចក្នុងប្រធានគណៈកម្មការជំនាញខ្លះៗ និងមានខ្ទង់ថវិកាសម្រាប់គណបក្សប្រឆាំងផងដែរ ។

## តំណាងរាស្ត្រស្នើឱ្យរាជរដ្ឋាភិបាលបំភ្លឺរឿងវិបត្តិសេដ្ឋកិច្ច និង ដីធ្លី

នៅក្នុងខែមករានេះ ទាំងតំណាងរាស្ត្រគណបក្សកាន់អំណាច និងប្រឆាំងមានភាពសកម្មក្នុងការតាមដានសកម្មភាពរាជរដ្ឋាភិបាល និងដោះស្រាយបញ្ហាដែលប្រទេសកំពុងប្រឈម ។ អ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ី និង សិទ្ធិមនុស្ស បានផ្ញើលិខិតផ្លូវការជូនរាជរដ្ឋាភិបាល ដោយផ្តល់អនុសាសន៍ដើម្បីទប់ទល់នឹងវិបត្តិសេដ្ឋកិច្ចក្នុងប្រទេស និងឱ្យរាជរដ្ឋាភិបាលបំភ្លឺពីវិធានការនានា ដើម្បីការពារកម្ពុជា ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ។

ចំណែកតំណាងរាស្ត្រគណបក្សកាន់អំណាចបានស្នើរាជរដ្ឋាភិបាលជួយដោះស្រាយ និងពិនិត្យមើលពីជម្លោះដីធ្លីនៅតំបន់ដីក្រហម ។ ទោះបីយ៉ាងណា រហូតដល់ចុងខែ មករា នេះនៅមិនទាន់ឃើញមានដំណោះស្រាយនៅឡើយទេ ។

ថ្ងៃទី២៨ខែមករា តំណាងរាស្ត្រនៃគណបក្សប្រឆាំងទាំងពីរគឺ សមរង្ស៊ី និង សិទ្ធិមនុស្ស បានធ្វើលិខិតរួមគ្នាដាក់សំណួរដល់នាយករដ្ឋមន្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជុំវិញការធ្លាក់ថ្លៃនៃតម្លៃផលិតផលកសិកម្ម ដែលកំពុងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រាក់ចំណូលរបស់ប្រជាកសិករ និងវិធានការនានារបស់រាជរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហានេះ ។

នៅថ្ងៃទី២៧ ខែមករាដដែល អ្នកតំណាងរាស្ត្រ **សុន ឆ័យ** ក៏បានដាក់លិខិតជូនរដ្ឋមន្ត្រីក្រសួង **សេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ស្នើឱ្យចូលមកបំភ្លឺនៅរដ្ឋសភាចំពោះវិធានការច្បាស់លាស់របស់រាជរដ្ឋាភិបាលចំពោះវិបត្តិហិរញ្ញវត្ថុពិភពលោក ដែលកំពុងតែជះឥទ្ធិពលមកលើកម្ពុជា ។

ការស្នើរដ្ឋមន្ត្រីមកបំភ្លឺនៅរដ្ឋសភាបានធ្វើឡើងប៉ុន្មានថ្ងៃក្រោយពីអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** បានស្នើឱ្យរាជរដ្ឋាភិបាលបម្រុងទុកប្រាក់ប្រមាណ ៥០០លានដុល្លារអាមេរិច ដើម្បីជួយដល់សេដ្ឋកិច្ចកម្ពុជារួមមានវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការបញ្ចុះពន្ធដារ និងការផ្តល់ប្រាក់កម្ចី ។

អ្នកនាំពាក្យរាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងពត៌មាន ឯកឧត្តម **ខៀវកាញារិទ្ធ** និង ប្រធានគណៈកម្មការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រដ្ឋសភា អ្នកតំណាងរាស្ត្រ **ជាម យៀប** ត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីថា រាជរដ្ឋាភិបាលបានត្រៀមប្រាក់បម្រុងទុក ៣០០លានដុល្លារអាមេរិច ដែលត្រៀមសំរាប់គ្រោះមហន្តរាយទៅជួយជំរុញដល់កំណើនសេដ្ឋកិច្ច តែមិនទាន់បានព្រមព្រៀងនៅឡើយទេសំរាប់ពតិមានលំអិត ។

អ្នកតំណាងរាស្ត្រ **សុន ឆ័យ** បារម្ភថា ការសាយភាយនៃវិបត្តិហិរញ្ញវត្ថុអាចធ្វើឱ្យកម្មករ កម្មការនី អត់ការងារធ្វើដោយសាររោងចក្រមួយចំនួនបិទទ្វារ ។

លោក វ៉ាន់ ស៊ូអៀង ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជាត្រូវបានប្រព័ន្ធផ្សព្វផ្សាយស្រង់សម្តីថា អ្នកបញ្ជាទិញផលិតផលកាត់ដេរពីកម្ពុជាមានត្រឹមតែខែមីនាប៉ុណ្ណោះ ។ ប្រសិនបើរោងចក្រកាត់ដេរត្រូវផ្អាកការផលិតនោះនឹងនាំឱ្យកម្មករប្រមាណពី ៥០ពាន់ ទៅ ៦០ពាន់នាក់ត្រូវបាត់បង់ការងារហើយប្រជាជនប្រហែលជាង ៤លាន នាក់អាចនឹងប៉ះពាល់ដោយប្រយោល ។

កន្លងមកនេះរោងចក្រប្រមាណ ៦០ បានបិទទ្វាររួចហើយនៅដើមឆ្នាំ ២០០៩នេះ ធ្វើឱ្យកម្មករ ២៥ ពាន់នាក់បាត់បង់ការងារហើយ។ ហើយនៅមានរោងចក្រ ២០ទៀតអាចនឹងត្រូវបិទ ឬបិទបណ្ដោះអាសន្ន។

នៅចុងខែនេះដែរ ប្រធានរដ្ឋសភា សម្ដេច **ហេង សំរិន** បានដាក់លិខិតទៅអភិបាលរាជធានីភ្នំពេញឱ្យជួយដោះស្រាយបញ្ហាជម្លោះដីធ្លីនៅតំបន់ដីក្រហម ដែលមានទីតាំងឆ្វេងមុខវិមានរដ្ឋសភា។

ការអន្តរាគមន៍នេះបានធ្វើឡើងបន្ទាប់ពីប្រជាពលរដ្ឋនៅតំបន់ដីក្រហមដែលត្រូវគេបណ្ដេញចេញពីទីលំនៅរបស់ខ្លួន ដែលត្រូវបានឈូសឆាយដោយក្រុមហ៊ុនអភិវឌ្ឍន៍ 7NG ។

ក្នុងលិខិតមួយផ្សេងទៀត អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មណ្ឌលកំពតក៏បានផ្ញើលិខិតជូនសម្ដេច **ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជាជួយអន្តរាគមន៍កុំឱ្យមានការវាយកំទេចសណ្ឋាគារ រណសិរ្ស ដែលជារបស់គណបក្សប្រជាជនកម្ពុជាដោយសណ្ឋាគារនេះគួរទុកជាតំបន់បេតិកភ័ណ្ឌដោយវានៅក្បែរព្រះបរមរាជាវាំងផងដែរ។

## ដំណើរការសម័យប្រជុំសភាពេញអង្គ

រដ្ឋសភាបានបញ្ចប់សម័យប្រជុំលើកទី១ (ពីខែតុលា ដល់ ខែធ្នូ ឆ្នាំ២០០៨) នីតិកាលទី៤ របស់ខ្លួនកាលពីខែធ្នូ។ ក្នុងសម័យប្រជុំលើកទី១នេះ រដ្ឋសភាបានប្រជុំពេញអង្គតែក្នុងខែតុលា និងវិច្ឆិកា ប៉ុណ្ណោះដែលមានចំនួន ១០ព្រឹក។ ក្នុងកិច្ចប្រជុំទាំង ១០ព្រឹកនេះ រដ្ឋសភាបានអនុម័តលើរបៀបវារៈចំនួន ១៦ ក្នុងនោះ **៤ ជាសេចក្ដីព្រាងច្បាប់** និង បោះឆ្នោតទុកចិត្តនានាមានចំនួន ១២។

ក្នុងសម័យប្រជុំលើកទី១នៃនីតិកាលទី៤នេះ មានតំណាងរាស្ត្រមកពី ៣ គណបក្សប៉ុណ្ណោះដែលបានឡើងបញ្ចេញមតិ។ មានអ្នកតំណាងរាស្ត្រ គណបក្សសមរង្ស៊ី ចំនួន ៥រូប បានឡើងបញ្ចេញមតិចំនួន ១៤ លើក ស្មើនឹង ២១២នាទី (ស្មើនឹង ៦៦% នៃរយៈពេលបញ្ចេញមតិសរុប ៣២២នាទី)។ ការបញ្ចេញមតិរបស់គណបក្ស សមរង្ស៊ី ភាគច្រើន គឺជាការរិះគន់ទៅលើភាពមិនពេញលក្ខណៈនៃសេចក្ដីព្រាងច្បាប់ និងរិះគន់ដល់ការងាររាជរដ្ឋាភិបាល និងលើកឡើងពីកង្វល់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានជាដើម។

ចំណែកអ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនមាន ៧រូប ( នៃអ្នកតំណាងរាស្ត្ររបស់គណបក្សនេះសរុប ៩០រូប ) បានឡើងបញ្ចេញមតិសរុបតែ ៩១នាទី (ស្មើនឹង ២៨%នៃរយៈពេលបញ្ចេញមតិដោយអ្នកតំណាងរាស្ត្រសរុបទាំងអស់)។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាភាគច្រើន គឺការពារសេចក្ដីព្រាងច្បាប់ និងការពាររាជរដ្ឋាភិបាលពីការរិះគន់របស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី។

អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិមានតែ ១រូប (ក្នុងចំនោម២រូប) ដែលបានឡើងបញ្ចេញមតិ ១៩នាទី (២លើក) ខណៈដែលតំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចមិនបានឡើងបញ្ចេញមតិទេ បើទោះបីខ្លួនចូលរួមក្នុងក្រុមបញ្ចេញមតិជាមួយគណបក្សប្រជាជនកម្ពុជាក៏ដោយ។

គ្មានអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សណាម្នាក់បានឡើងបញ្ចេញមតិនោះទេ ព្រោះមិនអាចមានលទ្ធភាពបង្កើតក្រុមបញ្ចេញមតិក្នុងរដ្ឋសភា ដែលតម្រូវឱ្យមានយ៉ាងតិច ១០រូប ហើយតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្សក៏មិនបានចូលរួមជាមួយក្រុមបញ្ចេញមតិរបស់គណបក្សផ្សេងទៀតដែរ។